ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការពារជាតិ

ថ្ងៃអង្គារ ៧កើត ខែមាឃ ឆ្នាំរកា នព្វស័ក ព.ស ២៥៦១
រាជធានីភ្នំពេញថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០១៨

**សារជូនពរ**

**សូមគោរពជូន**

**សម្តេចអគ្គមហាសេនាបតីតេជោ សាយ ឈុំ ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា**
**ក្នុងពិធីចម្រើនជន្មាយុគម្រប់ ៧៣ ឈានចូល ៧៤ ឆ្នាំ**

**សម្តេចអគ្គមហាសេនាបតីតេជោ ប្រធានព្រឹទ្ធសភា និងលោកជំទាវ ជាទីគោរពដ៏ខ្ពង់ខ្ពស់ !**

ក្នុងឱកាសដ៏ឧត្តុង្គឧត្តម នៃពិធីចម្រើនជន្មាយុគម្រប់៧៣ ឈានចូល៧៤ឆ្នាំ ដែលនឹងប្រព្រឹត្តទៅនាថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០១៨នេះ តាងនាមថ្នាក់ដឹកនាំក្រសួងការពារជាតិ ព្រមទាំងនាយទាហាន នាយទាហានរង និងពលទាហានទាំងអស់ នៃកងយោធពលខេមរភូមិន្ទ ក្នុងនាមខ្ញុំនិងភរិយា សូមជូននូវសព្ទសាធុការពរជ័យ បវរសួស្តី សិរីមង្គល វិបុលសុខ មហាប្រសើរ ជូនចំពោះ **សម្តេចអគ្គមហាសេនាបតីតេជោ** និង**លោកជំទាវ** សូមទទួលបាននូវសុខភាពល្អបរិបូរណ៍ កម្លាំងមាំមួនខ្លាំងក្លា បញ្ញាញាណវាងវៃ ជន្មាយុយឺនយូរ ដើម្បីបន្តដឹកនាំស្ថាប័ន-ព្រឹទ្ធសភាឲ្យមានការរីកចម្រើនថែមទៀត។

យើងខ្ញុំទាំងអស់គ្នា សូមសម្តែងនូវសេចក្តីគោរព និងកោតសរសើរយ៉ាងក្រៃលែងនូវការដឹកនាំរបស់**សម្តេច-អគ្គមហាសេនាបតីតេជោ** ធ្វើឲ្យស្ថាប័នព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជាសម្រេចបាននូវស្នាដៃ និងសមិទ្ធផលជាច្រើន ដែលឆ្លុះបញ្ចាំងឲ្យឃើញពីការខិតខំប្រឹងប្រែងពុំខ្លាចនឿយហត់របស់ **សម្តេច** ក្នុងភាពជាអ្នកដឹកនាំនៅក្នុងស្ថាប័នព្រឹទ្ធសភា ដែលជាស្ថាប័នកំពូលរបស់ជាតិឲ្យទទួលបានជោគជ័យនៅគ្រប់កាលៈទេសៈ។

ជាថ្មីម្តងទៀត ក្នុងនាមថ្នាក់ដឹកនាំក្រសួងការពារជាតិ និងកងយោធពលខេមរភូមិន្ទទាំងមូល ក្នុងនាមខ្ញុំនិងភរិយា សូមបួងសួងចំពោះគុណបុណ្យព្រះរតនត្រ័យ និងវត្ថុស័ក្តិសិទ្ធិទាំងឡាយក្នុងលោក តាមជួយបីបាច់ថែរក្សាប្រោះព្រំសព្ទសាធុការពរជ័យ ជូនចំពោះ **សម្តេចអគ្គមហាសេនាបតីតេជោ** និង**លោកជំទាវ** ព្រមទាំងបុត្រាបុត្រី **ចៅប្រុសចៅស្រី** ជាទីស្រឡាញ់ សូមបានសមប្រកបនូវពុទ្ធពរទាំងបួនប្រការគឺ **អាយុ វណ្ណៈ សុខៈ ពលៈ** កុំបីឃ្លៀងឃ្លាតឡើយ ។

សូម **សម្តេចអគ្គមហាសេនាបតីតេជោ សាយ ឈុំ ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា** និង**លោកជំទាវ** មេត្តាទទួលនូវគារវភក្តីភាពដ៏ខ្ពង់ខ្ពស់បំផុតអំពីយើងខ្ញុំ។

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**

សម្តេចពិជ័យសេនា **ទៀ បាញ់**